ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៤៦ អយក. ឯជណា

សេចក្តីជូនដំណឹង
ស្តីពី
កិច្ចសហការរវាងក្រសួងអប់រំ យុវជន និងកីឡា ជាមួយក្រសួងព័ត៌មាន ក្នុងការរៀបចំផលិត និងផ្សព្វផ្សាយកម្មវិធី "ការសិក្សាពីចម្ងាយ" និង "ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក"

ក្រសួងអប់រំ យុវជន និងកីឡា មានកិត្តិយសសូមជម្រាបជូនសិស្សានុសិស្ស មាតាបិតា អ្នកអាណាព្យាបាលសិស្ស និងសាធារណជនទាំងអស់មេត្តាជ្រាបថា តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីជាជំនួយដល់ការសិក្សារបស់សិស្សានុសិស្សទាំងអស់នៅថ្នាក់មត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ ក្នុងអំឡុងពេលនៃការពន្យាការចូលរៀនឡើងវិញក្រោយវិស្សមកាលតូច សម្រាប់គ្រឹះស្ថានសិក្សាគ្រប់កម្រិត គ្រប់ប្រភេទ ទាំងសាធារណៈនិងឯកជន ក្រសួងអប់រំ យុវជន និងកីឡានិងក្រសួងព័ត៌មាន បានសហការរៀបចំផលិត និងផ្សព្វផ្សាយកម្មវិធី "ការសិក្សាពីចម្ងាយ" និង "ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក" តាមរយៈការចាក់ផ្សាយវីដេអូនៃការបង្រៀនគ្រប់កម្រិតថ្នាក់ លើប្រព័ន្ធទូរទស្សន៍ជាតិកម្ពុជាកាណាល់ **ទ.ទ.ក/២** ព្រមទាំងការផ្សាយបន្តតាមបណ្តាញទូរទស្សន៍ខ្សែកាបរាជធានី-ខេត្ត វេទិកាអប់រំឌីជីថលក្រសួងអប់រំ យុវជន និងកីឡាកំពុងមានស្រាប់ និងលើ App របស់ក្រសួងព័ត៌មាន។ កិច្ចសហការនេះ ជាការធ្វើឱ្យកាន់តែសម្បូរបែប និងកាន់តែប្រសើរឡើងនូវការផ្តល់សេវាអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាប័ន្ន លើកកម្ពស់ប្រសិទ្ធភាពស្វ័យសិក្សា និងការសិក្សាពីចង្ងាយសម្រាប់សិស្សានុសិស្សគ្រប់រូបនាពេលបច្ចុប្បន្ន។

ក្រសួងអប់រំ យុវជន និងកីឡា សូមសិស្សានុសិស្ស មាតាបិតា អ្នកអាណាព្យាបាល និងសាធារណជនទាំងអស់មេត្តាយកចិត្តទុកដាក់លើវិធីទទួលបានកម្មវិធី "ការសិក្សាពីចម្ងាយ" និង "ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក" លើប្រព័ន្ធទូរទស្សន៍ជាតិកម្ពុជា បណ្តាញទូរទស្សន៍ខ្សែកាប វេទិកាអប់រំឌីជីថលរបស់ក្រសួងអប់រំ យុវជន និងកីឡានិង App របស់ក្រសួងព័ត៌មាន ដូចតទៅ ៖

១. ការចាក់ផ្សាយវីដេអូនៃការបង្រៀនតាមកញ្ចក់ទូរទស្សន៍

ចាប់ពីថ្ងៃច័ន្ទ ទី២០ ខែមេសា ឆ្នាំ២០២០នេះតទៅ សិស្សានុសិស្សគ្រប់កម្រិតសិក្សា និងគ្រប់ភូមិសិក្សានៅទូទាំងព្រះរាជាណាចក្រកម្ពុជា នឹងអាចទស្សនាវីដេអូនៃការបង្រៀន នៅលើប្រព័ន្ធទូរទស្សន៍ដូចខាងក្រោម ៖

- ទូរទស្សន៍ជាតិកម្ពុជាទី២ **ទទក២** ឬ TVK2 ដែលជាប៉ុស្តិ៍ទូរទស្សន៍ទើបតែបង្កើតថ្មី សម្រាប់បម្រើដល់ការផ្សព្វផ្សាយស្តីពីការអប់រំ
- ទូរទស្សន៍ផ្កាយរណបតេជោឌីជីវី Decho DTV ប៉ុស្តិ៍លេខ២២
- ទូរទស្សន៍ខ្សែកាបនៅទូទាំង២៥រាជធានី-ខេត្ត ដែលមានចំនួន៥៥ប៉ុស្តិ៍ថ្មី ដែលផ្សាយបន្តពីទូរទស្សន៍ជាតិកម្ពុជា**ទទក២** ឬ TVK2 (សូមមើលតារាងឧបសម្ព័ន្ធទី១នៃសេចក្តីជូនដំណឹងនេះ នូវឈ្មោះក្រុមហ៊ុនទូរទស្សន៍ខ្សែកាប និងលេខប៉ុស្តិ៍ នៅតាមរាជធានី-ខេត្តនីមួយៗ)

ការចាក់ផ្សាយវីដេអូនៃការបង្រៀននៅលើប្រព័ន្ធទូរទស្សន៍ខាងលើ នឹងប្រព្រឹត្តទៅ២៤ម៉ោងក្នុងមួយថ្ងៃ និងជារៀងរាល់ថ្ងៃ ដែលក្នុងនោះការចាក់ផ្សាយចាប់ពីម៉ោង ៨:០០ព្រឹក ដល់ម៉ោង២៤:០០យប់ ជាការផ្សាយវីដេអូនៃការបង្រៀនជាប្រចាំ ហើយពីម៉ោង២៤:០០យប់ ដល់ម៉ោង០៨:០០ព្រឹក ជាការចាក់ផ្សាយឡើងវិញ (សូមមើលតារាងឧបសម្ព័ន្ធទី២នៃសេចក្តីជូនដំណឹងនេះ នូវកម្មវិធីពិស្តារនៃការបញ្ចាំងវីដេអូនៃការបង្រៀនតាមមុខវិជ្ជា និងថ្នាក់នីមួយៗ)។ សិស្សានុសិស្សនៅថ្នាក់ទី៩ និងថ្នាក់ទី១២ នឹងអាចទស្សនាវីដេអូនៃ ការបង្រៀនរយៈពេល៣ម៉ោងក្នុងមួយថ្ងៃ ដោយយោងទៅលើការចាំបាច់ជាថ្នាក់ប្រឡង។

២. ការបង្ហោះវីដេអូនៃការបង្រៀនតាម App របស់ក្រសួងព័ត៌មាន

ក្រសួងព័ត៌មាន បានរៀបចំបង្កើត Feature មួយនៅក្នុង App របស់ក្រសួង ដែលសិស្សានុសិស្សអាចចូលទៅទស្សនាវីដេអូនៃការបង្រៀន តាមកម្រិតថ្នាក់ មុខវិជ្ជា និងមេរៀន តាមតម្រូវការរបស់ខ្លួន។ វីដេអូនៃការបង្រៀនដែលមានបង្ហោះនៅក្នុង App របស់ក្រសួងព័ត៌មាន គឺដូចគ្នាទៅនឹងវីដេអូដែលបញ្ចាំងនៅលើកញ្ចក់ទូរទស្សន៍។ សិស្សានុសិស្សអាច Download App របស់ក្រសួងព័ត៌មានមកក្នុង Smartphone ហើយ ចូលទស្សនាវីដេអូនៃការបង្រៀន ដោយចុចនៅលើប៊ូតុងដែលមានរូបសញ្ញាក្រសួងអប់រំ យុវជន និងកីឡា។

៣. វេទិកាអប់រំឌីជីថលរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលកំពុងមានស្រាប់

ក្រៅពីការទស្សនាវីដេអូនៃការបង្រៀនតាមទូរទស្សន៍ និងនៅក្នុង App របស់ក្រសួងព័ត៌មាន សិស្សានុសិស្សទាំងអស់នៅតែអាចទស្សនាវីដេអូ នៅលើវេទិកាអប់រំឌីជីថលចំនួន៣ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានរៀបចំតាំងពីខែមីនា ឆ្នាំ២០២០៖

- បណ្តាញ YouTube ផ្លូវការរបស់ក្រសួង៖ www.youtube.com/moeys ដែលនឹងមានវីដេអូបង្រៀនទាំងអស់ សម្រាប់សិស្សានុសិស្សអាចសិក្សាបានទៅតាមពេលវេលាជាក់ស្តែងរបស់ខ្លួន
- ទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួង៖ www.facebook.com/moeys.gov.kh ដែលធ្វើការផ្សព្វផ្សាយជារៀងរាល់ថ្ងៃ

- មជ្ឈមណ្ឌលសិក្សាអេឡិចត្រូនិករបស់ក្រសួង៖ www.elearning.moeys.gov.kh ដោយសិស្សានុសិស្សអាចចូលទៅសិក្សាបាន ដោយចូលទៅជ្រើសរើសវគ្គសិក្សាឬមេរៀនដែលត្រូវសិក្សាដោយឥតគិតថ្លៃ និងមិនចាំបាច់ចុះឈ្មោះ (ចូលជាភ្ញៀវ)។

បន្ថែមលើមធ្យោបាយទាំងអស់ខាងលើ សិស្សានុសិស្សអាចមានជម្រើសបន្ថែមទៀតក្នុងការ ទស្សនាវីដេអូនៃការបង្រៀន ដោយការ Download កម្មវិធី App E-School Cambodia សម្រាប់គ្រប់ថ្នាក់ និងគ្រប់កូមិសិក្សា ដែលជាកិច្ចសហការរវាងក្រសួងអប់រំ យុវជន និងកីឡា ក្រុមហ៊ុន E-School Cambodia និងសហភាពសហព័ន្ធយុវជនកម្ពុជា។ ក្រៅពីនេះ ក្រុមហ៊ុន Postcar ដែលមាន App សម្រាប់ទូរស័ព្ទដៃ Wiki School បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការបង្ហោះវីដេអូបង្រៀនដែលផលិតដោយក្រសួងអប់រំ យុវជន និងកីឡា ផងដែរ។

ជាមួយនឹងភាពសម្បូរបែបនៃមធ្យោបាយសម្រាប់ការរៀនតាមកម្មវិធី "ការសិក្សាពីចម្ងាយ" និង "ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក" ក្រសួងអប់រំ យុវជន និងកីឡា សូមមាតាបិតា និងអ្នកអាណាព្យាបាលសិស្សទាំងអស់ មេត្តាជួយជាស់តឿន ក្រើនរំលឹកដល់កូនចៅជាសិស្សានុសិស្ស ឱ្យខិតខំរៀនសូត្រដោយខ្លួនឯងក្នុងពេលសម្រាកនៅផ្ទះ ជាមួយសៀវភៅសិក្សាគោលស្របតាមកម្មវិធីរបស់ក្រសួង ក៏ដូចជា "ការសិក្សាពីចម្ងាយ" និង "ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក" ដោយការយកចិត្តទុកដាក់ខ្ពស់បំផុត។

ថ្ងៃ ៨ កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២០
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

ចម្លងជូន៖
- សាលារាជធានី-ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទទីស្តីការក្រសួង
"ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត
"ដើម្បីមុខការ"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានរដ្ឋបាល

ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍ស្តីពី

ការចូលរួមរបស់ទូរទស្សន៍ខ្សែកាបរាជធានី - ខេត្ត

ក្នុងការផ្សាយបន្តពី **ឧ.ឧ.ក/២** កម្មវិធី " **ការសិក្សាពីចម្ងាយ និង ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច** "

ល.រ	រាជធានី - ខេត្ត	ចំនួន	ឈ្មោះទូរទស្សន៍ខ្សែកាប	ផ្សាយកាណាល់លេខ
1	រាជធានី ភ្នំពេញ	1	ទូរទស្សន៍ខ្សែកាបរាជធានីភ្នំពេញ PPCTV	1
		2	ទូរទស្សន៍ខ្សែកាបកម្ពុជា CCTV	40
2	ខេត្ត កំពង់ចាម	3	ខ្សែកាប .CAM.TV/ Digital	30
		4	ខ្សែកាប.CAM.TV/Analog	24
3	ខេត្ត ត្បូងឃ្មុំ	5	ខ្សែកាបក្រុងសួង	16
		6	ខ្សែកាប អមធីវី	22
4	ខេត្ត កំពង់ធំ	7	ខ្សែកាបស្ទឹងសែន	29
		8	ខ្សែកាបអង្គរ	58
		9	ខ្សែកាបស្រុកស្ទោង	14
5	ខេត្ត ព្រះវិហារ	10	ខ្សែកាប សូសបញ្ញា	22
6	ខេត្ត ពោធិសាត់	11	ខ្សែកាប ពោធិសាត់	5
		12	ខ្សែកាបស្រុកកណ្តៀង	5
		13	ខ្សែកាបស្រុក ក្រវ៉ាញ	5
7	ខេត្ត កំពង់ឆ្នាំង	14	ខ្សែកាប ខេស៊ី KC	31
8	ខេត្ត រតនគីរី	15	ខ្សែកាបរតនគីរី	3
9	ខេត្ត កែប	16	ខ្សែកាប Power Supply	4
10	ខេត្ត បាត់ដំបង	17	ខ្សែកាបហង្សមាសបាត់ដំបង	2
		18	ខ្សែកាប CAM.TV/Digital	48
		19	ខ្សែកាប CAM.TV/Analog	55

		20	ខ្សែកាប ស្រុកសំពៅលូន	8
11	ខេត្ត ព្រៃវែង	21	ខ្សែកាបព្រៃវែង	1
12	ខេត្ត ព្រះសីហនុ	22	ខ្សែកាបពន្លឺថ្មី (វាលរេញ)	7
		23	ខ្សែកាបព្រៃនប់ (ឃុំព្រៃនប់)	17
		24	ខ្សែកាបខេមរា (ស្រុកស្ទឹងហាវ)	1
		25	ខ្សែកាបពន្លឺផ្កាយ (ក្រុងព្រះសីហនុ)	1
		26	ខ្សែកាបខេមភូម (ក្រុងព្រះសីហនុ)	16
13	ខេត្ត កំពង់ស្ពឺ	27	ខ្សែកាបក្រុងច្បារមន (លោក ហោង សង្ហា)	39
		28	ខ្សែកាបក្រុងច្បារមន (លោកស្រី ឱក មករា)	4
		29	ខ្សែកាបថ្នល់ទទឹង	77
14	ខេត្ត សៀមរាប	30	ខ្សែកាបអង្គរ	19
		31	ខ្សែកាបក្រុងសៀមរាប	18
		32	ខ្សែកាបស្រុកក្រឡាញ់ Analog	56
		33	ខ្សែកាបស្រុកសូត្រនិគម Analog	56
		34	ខ្សែកាបស្រុកជីក្រែង Analog	56
15	ខេត្ត ក្រចេះ	35	ខ្សែកាបក្រុងក្រចេះ(ហោង ហោង)	1
		36	ខ្សែកាបលាងស្រីមុំ	11
		37	ខ្សែកាបស្រុកស្នួល	17
16	ខេត្តកោះកុង	38	ខ្សែកាបក្រុងខេមរភូមិន្ទកោះកុង	7
17	ខេត្ត កណ្តាល	39	ខ្សែកាប PPCTV	1
18	ខេត្ត ឧត្តរមានជ័យ		ប្រជាពលរដ្ឋមើលតាម តេជោ.DTV	22
19	ខេត្ត មណ្ឌលគីរី	40	ខ្សែកាបក្រុងសែនមនោរម	38
20	ខេត្ត ប៉ៃលិន	41	ខ្សែកាបប៉ៃលិន	24
		42	ខ្សែកាប ព្រំ	24
21	ខេត្ត បន្ទាយមានជ័យ	43	ខ្សែកាប ក្រុងសិរីសោភណ្ឌ	27
		44	ខ្សែកាប ក្រុងប៉ោយប៉ែត	27

		45	ខ្សែកាប ស្រុកមង្គលបុរី	27
		46	ខ្សែកាប ទីរួមស្រុកអូរជ្រៅ	27
22	ខេត្ត ស្វាយរៀង	47	ខ្សែកាប ក្រុងស្វាយរៀង(ហួយ ម៉ែង)	60
		48	ខ្សែកាប កងបាវិត	35
23	ខេត្ត ស្ទឹងត្រែង	49	ខ្សែកាប ខេត្តស្ទឹងត្រែង	18
24	ខេត្ត តាកែវ	50	ខ្សែកាប បកែវ (ក្រុងដូនកែវ)	3
		51	ខ្សែកាប បកែវ (ស្រុកអង្គតាសោម)	3
		52	ខ្សែកាប ក្រាំឆ្នារ	77
		53	ខ្សែកាប ស្រុកបាទី	77
		54	ខ្សែកាបព្រះបាទជាន់ជុំ គីរីវង់	15
25	ខេត្ត កំពត	55	ខ្សែកាប តារាវីឌីអូ. ខេត្តកំពត	1

សូមគោរពរាយការណ៍ជម្រាបជូន **ឯកឧត្តម រដ្ឋមន្ត្រី** ជ្រាបតាមការគួរ ។

ថ្ងៃអាទិត្យ ១២ រោច ខែ ចេត្រ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

ត្រូវនឹងថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០២០

ប្រធានក្រុមការងារ Distance Learning and E-Learning ក្រសួងព័ត៌មាន

ហត្ថលេខា

ភម គុណាឋឌ្ឍន៍